ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ថ្ងៃ ពុធ ០៩ កើត ខែ ចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣*
*រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០២០*

# សេចក្តីជូនដំណឹងសម្រាប់សារព័ត៌មាន
## ស្តីពី
## ជំនួបពិភាក្សាការងាររវាងឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយនិងឯកឧត្តម Dmitry Tsvetkov ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសហព័ន្ធរុស្ស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា

នាព្រឹកថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០២០, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានទទួលជួបពិភាក្សាការងារជាមួយឯកឧត្តម Dmitry Tsvetkov ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសហព័ន្ធរុស្ស៊ីប្រចាំព្រះរាជាណាចក្រកម្ពុជា នាឱកាសដែលឯកឧត្តមត្រូវបញ្ចប់បេសកកម្មការទូតនៅកម្ពុជា ក៏ដូចជាដើម្បីបន្តពង្រឹងបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការទ្វេភាគី កម្ពុជា-រុស្ស៊ី ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងវាយតម្លៃខ្ពស់ចំពោះប្រជាជន និងរដ្ឋាភិបាលនៃសហព័ន្ធរុស្ស៊ី ដែលបានចូលរួមចំណែកយ៉ាងសកម្មដល់ការកសាងសន្តិភាព និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា តាំងពីបាតដៃទទេ រហូតមកដល់បច្ចុប្បន្ននេះ ។ សមិទ្ធិផលប្រកបដោយផ្លែផ្កានៃការអភិវឌ្ឍដែលកម្ពុជាទទួលបាន មិនអាចកាត់ផ្តាច់ពីការគាំទ្ររបស់រដ្ឋាភិបាលរុស្ស៊ី និងដៃគូអភិវឌ្ឍន៍នានា ។ ជាក់ស្តែង, ក្នុងអាណត្តិការទូតរបស់ឯកឧត្តម Dmitry Tsvetkov នៅកម្ពុជា, ចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ កម្ពុជា និងរុស្ស៊ី ត្រូវបានពង្រឹង និងពង្រីកជាបន្តបន្ទាប់ ហើយបាននាំមកនូវលទ្ធផលដ៏ត្រចះត្រចង់ជាពិសេស កិច្ចសហប្រតិបត្តិការក្នុងវិស័យសេដ្ឋកិច្ច, ពាណិជ្ជកម្ម, វិនិយោគ និងការអភិវឌ្ឍធនធានមនុស្ស ។

នាឱកាសនោះដែរ, ឯកឧត្តម Dmitry Tsvetkov បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការផ្តល់កិច្ចសហប្រតិបត្តិការយ៉ាងល្អប្រពៃពីក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់កម្ពុជា ក្នុងអាណត្តិដែលឯកឧត្តមបានមកបំពេញបេសកកម្មការទូតនៅព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើឱ្យបេសកកម្មការទូតរបស់ឯកឧត្តមទទួលបានជោគជ័យ ។ ឯកឧត្តមឯកអគ្គរដ្ឋទូតបានគូសបញ្ជាក់ផងដែរថា រដ្ឋាភិបាលសហព័ន្ធរុស្ស៊ីនៅតែបន្តជួយគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា លើគ្រប់ផ្នែក ជាពិសេស ការបង្កើនការផ្តល់អាហារូបករណ៍ដល់និស្សិតកម្ពុជាទៅបន្តការសិក្សានៅសហព័ន្ធរុស្ស៊ីបន្ថែមទៀតជារៀងរាល់ឆ្នាំ ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ក៏បានជម្រាបឯកឧត្តមឯកអគ្គរដ្ឋទូត Dmitry Tsvetkov អំពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលកម្ពុជាចំពោះវិនិយោគិនទាំងអស់ ខណៈដែលកម្ពុជាកំពុងចាត់វិធានការ

ធ្វើកំណែទម្រង់, ពង្រីកទីផ្សារ, ជំរុញវិមាត្រសេដ្ឋកិច្ច, និងគាំទ្រការប្រកួតប្រជែងក្នុងក្របខ័ណ្ឌទីផ្សារសេរីប្រកបដោយភាពត្រឹមត្រូវ និងយុត្តិធម៌ ។ រាជរដ្ឋាភិបាលកម្ពុជា ផ្ដល់ការលើកទឹកចិត្តដល់ការវិនិយោគ និងខិតខំបង្កបរិយាកាសឱ្យអ្នកវិនិយោគមានភាពជឿជាក់ក្នុងការដាក់ទុនវិនិយោគនៅកម្ពុជា ។ ដោយសារប្រទេសទាំងពីរបានចុះកិច្ចព្រមព្រៀងស្ដីពីការជំរុញ និងការការពារទៅវិញទៅមកនៃការវិនិយោគរួចហើយ ភាគីទាំងពីរបានពិភាក្សាអំពីយន្តការ ក្នុងការរៀបចំកិច្ចព្រមព្រៀងស្ដីពីការជៀសវាងការយកពន្ធត្រួតគ្នារវាងព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធរុស្ស៊ី ដើម្បីទាក់ទាញវិនិយោគិនរុស្ស៊ីឱ្យមកវិនិយោគនៅកម្ពុជាកាន់តែច្រើនឡើងថែមទៀត ។

នៅក្នុងជំនួបនោះដែរ ភាគីទាំងពីរ ក៏បានពិភាក្សាអំពីឥទ្ធិពលនៃការរាតត្បាតនៃជម្ងឺកូវីត ១៩ ដែលបានធ្វើឲ្យមានផលប៉ះពាល់អវិជ្ជមានដល់សេដ្ឋកិច្ចនៃបណ្ដាប្រទេសនានាលើសកលលោក និងសេណារីយ៉ូមួយចំនួនសម្រាប់ដោះស្រាយ និងទប់ស្កាត់ចំពោះផលប៉ះពាល់មកលើសេដ្ឋកិច្ចកម្ពុជា ។

ជាទីបញ្ចប់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី បានជូនពរឯកឧត្តម **Dmitry Tsvetkov** ឱ្យទទួលបានជោគជ័យក្នុងតួនាទីថ្មីរបស់ឯកឧត្តមនាពេលខាងមុខ ។